ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សុខាភិបាល

៤20 សកប

លិខិតណែនាំ

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ជំរាបមក

លោកប្រធានមន្ទីរសុខាភិបាលគ្រប់ខេត្ត ក្រុង

និងលោកប្រធានគ្រប់អង្គភាពថ្នាក់កណ្តាល .

កម្មវត្ថុ : ការទទួលមន្ត្រីរាជការមកឲ្យចូលបំពេញការងារតាមប្រកាសផ្ទេររបស់ក្រសួង .

ដើម្បីធានាបែបក្នុងកម្មវត្ថុខាងលើនេះក្រសួងសូមធ្វើការណែនាំដូចខាងក្រោម :

- មន្ត្រីរាជការដែលបានការអនុញ្ញាតអោយផ្លាស់ប្តូរកន្លែងធ្វើការឬផ្ទេរអោយទៅបំពេញការងារនៅខេត្ត.ក្រុង.អង្គភាព ត្រូវមានវត្តមាននៅអង្គភាពតាមកាលបរិច្ឆេទដូចខាងក្រោមចាប់តាំងពីថ្ងៃចេញសេចក្តីប្រកាសរបស់ក្រសួង .
  - រយៈពេលមួយខែចំពោះខេត្ត.កោះកុង.ព្រះវិហារ.ស្ទឹងត្រែង.រតនគិរីនិងមណ្ឌលគិរី ។
  - រយៈពេល ២០ថ្ងៃ ចំពោះខេត្តវាលរាប ។
  - រយៈពេល ១៥ថ្ងៃ ចំពោះអង្គភាពថ្នាក់កណ្តាល ។

  កាលបរិច្ឆេទកំណត់នេះត្រូវគិតទាំងការផ្លាស់ចេញនិងផ្លាស់ចូល
- ក្រោយពីវត្តមានមន្ត្រីរាជការក្នុងករណីខាងលើមន្ទីរសុខាភិបាលខេត្ត.ក្រុង និង អង្គភាពថ្នាក់កណ្តាលត្រូវរៀបចំប្រគល់ ភារកិច្ចតាមការចាត់តាំងចៀសវាងការបង្អង់ពេលវេលា ។
- ក្នុងករណីដែលមន្ត្រីរាជការត្រូវអនុញ្ញាតអោយផ្ទេរចេញសាមុីអង្គភាពដើមត្រូវផ្តល់លិខិតចេញដំណើរដល់អង្គភាពថ្មីជាការ ចាំបាច់បន្ទាប់ពីសាមុីខ្លួនបានអនុញ្ញាតអោយផ្ទេរការងាររួចរាល់ហើយ ។
- ក្រោយពីរៀបចំបែងចែកកន្លែងធ្វើការរួចចេញលិខិតបង្គាប់ការងារ មន្ទីរសុខាភិបាលខេត្ត.ក្រុង អង្គភាពថ្នាក់កណ្តាល ត្រូវចម្លងផ្ញើរមកក្រសួងមួយច្បាប់ ។
- ចំពោះករណីមន្ត្រីរាជការដែលគ្មានវត្តមានហួសកាលបរិច្ឆេទខាងលើ មន្ទីរសុខាភិបាលខេត្ត.ក្រុងនិងអង្គភាពថ្នាក់កណ្តាលត្រូវ រាយការណ៍មកក្រសួងជាការចាំបាច់ដើម្បីក្រសួងមានវិធានការណ៍តាមច្បាប់ ។
- ក្រោយពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការដើម្បីចូលបំពេញការងារថ្មីនេះត្រូវតែផ្ញើរអោយសំណុំលិខិតផ្ទាល់ខ្លួនមន្ត្រីរាជការ (Dossir Personnel) ផ្ញើរមកក្រសួងមួយច្បាប់ ។

ដូចនេះដើម្បីអនុវត្តនេះក្រសួងមានជំនឿថា លោកប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុងនិងអង្គភាពថ្នាក់កណ្តាល និងយកចិត្តទុកដាក់អនុវត្តអោយបានល្អប្រសើរដើម្បីបំពេញអោយបានស្របតាមការគ្រប់គ្រងមន្ត្រីរាជការក្រោមឱវាទរបស់ខ្លួន ។

ភ្នំពេញ ថ្ងៃទី ២ ខែ 11 ១៩៩៥